**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១២ ស.សរ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១._**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ហៅកាត់ **គ.ស.ច.គ** ដូចខាងក្រោម៖

១-សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន អនុប្រធានអចិន្ត្រៃយ៍

៣-ឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **អ៊ុក គីមលេខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៤-ឯកឧត្តម **កើត រិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ អនុប្រធាន

៥-លោកជំទាវ **មឹន មាណវី** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន អនុប្រធាន

៦-ឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ អនុប្រធាន

៧-ឯកឧត្តម **ឈិត សុខុន** រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨-ឯកឧត្តមវេជ្ជបណ្ឌិត **តែ គុយស៊ាង** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

៩-ឯកឧត្តម **អ៊ុម អុច** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១០-ឯកឧត្តម **សួស គង់** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១១-ឯកឧត្តម **ឯល វ៉ាន់សារ៉ាត** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១២-ឯកឧត្តម **សៅ សុភាព** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

១៣-ឯកឧត្តម **គឹម ស៊ីថន** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

១៤-ឯកឧត្តម **ខា ម៉ូរ៉ា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

១៥-ឯកឧត្តម **អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គមនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៦-លោកជំទាវ **ប្រាក់ ច័ន្ទណាយ** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

១៧-ឯកឧត្តម **ម៉ែន សុផល** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១៨-ឯកឧត្តម **អ៊ុច ម៉ូរ៉ា** រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម សមាជិក

១៩-ឯកឧត្តមបណ្ឌិត **ឈុន សុភាព** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

២០-ឯកឧត្តម **អ៊ុង ផល្លី** អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

២១-លោកជំទាវ **ពុំ ចន្ទីនី** អគ្គលេខាធិការកាកបាទក្រហមកម្ពុជា សមាជិក

២២-ឯកឧត្តម **នូ វឌ្ឍនៈ** អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស សមាជិក

២៣-ឯកឧត្តម **ហេង រត្នពិសិដ្ឋ** អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ សមាជិក

២៤-ឯកឧត្តម **ឈួន ម៉័ន** អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក សមាជិក

២៥-ឧត្តមសេនីយ៍ទោ **ម៉ាន់ ច័ន្ទវឌ្ឍនា** នាយរងសេនាធិការដ្ឋាន កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក។

**ប្រការ២.**_

**គ.ស.ច.គ** ត្រូវអនុវត្តតួនាទី និងភារកិច្ច ដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

**ប្រការ៣.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។៤

**ប្រការ៤.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទីចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១១កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ